ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

និយ័តករមូលបត្រកម្ពុជា

លេខ:.....០០៥/២២...ន.ម.ក./គ.ណ.ន.

# គោលការណ៍ណែនាំ
# ស្តីពី
# ការបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០១២១/០០៣ ចុះថ្ងៃទី១៦ ខែមករា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, ព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, អនុក្រឹត្យលេខ ១១៣ អនក្រ.បក. ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០២១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អង្គភាពក្រោមឱវាទរបស់អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ, អនុក្រឹត្យលេខ ៩៧ អនក្រ.បក. ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា, អនុក្រឹត្យលេខ ៥៤ អនក្រ.បក. ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន, ប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ, ប្រកាសលេខ ០០៥/២០ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២០ ស្តីពីវិសោធនកម្មលើប្រកាសលេខ ០០៤/១៥ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៥ ស្តីពីការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងការជួញដូរឧបករណ៍និស្សន្ទ, ប្រកាសលេខ ០០៨/១៩ គ.ម.ក./ប្រ.ក. ចុះថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មឧបករណ៍និស្សន្ទ និងគោលការណ៍ណែនាំលេខ ០០១/២០ គ.ម.ក./គ.ណ.ន. ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២០ ស្តីពីទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ ទម្រង់កិច្ចព្រមព្រៀងអតិថិជន និងទម្រង់សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ សម្រាប់ការជួញដូរឧបករណ៍និស្សន្ទ ព្រមទាំងបទប្បញ្ញត្តិពាក់ព័ន្ធដទៃទៀត និងដើម្បីជួយសម្រួលដល់ការយល់ដឹងអំពីនីតិវិធី លក្ខខណ្ឌតម្រូវ និងកាតព្វកិច្ចរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទ ពាក់ព័ន្ធនឹងការស្នើសុំការអនុញ្ញាតប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ **និយ័តករមូលបត្រកម្ពុជា (ន.ម.ក.)** សម្រេចចេញគោលការណ៍ណែនាំស្តីពីការបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ដូចខាងក្រោម៖

## ១-នីតិវិធីនៃការដាក់ពាក្យស្នើសុំការអនុញ្ញាត

ឈ្មួញជើងសាឧបករណ៍និស្សន្ទដែលមានបំណងប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ត្រូវដាក់ពាក្យស្នើសុំការអនុញ្ញាតទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយ **ន.ម.ក.**។

អាសយដ្ឋាន : អគារ168F ផ្លូវ 598 សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ-កម្ពុជា
ទូរសព្ទ : ៨៥៥-២៣-៨៨៥-៦១១ ទូរសារ : ៨៥៥-២៣-៨៨៥-៦២២
Address : Building 168F, Street 598, Sangkat Chrang Chamreh 1, Khan Russey Keo, Phnom Penh, Cambodia
Phone : 855-23-885-611 Fax : 855-23-885-622
E-mail : info@serc.gov.kh Website: www.serc.gov.kh

**ន.ម.ភ.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំការអនុញ្ញាត និងពិនិត្យប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ។

**ន.ម.ភ.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់ឈ្មួញជើងសាឧបករណ៍និស្សន្ទអំពីការយល់ព្រម ឬបដិសេធលើការស្នើសុំនេះ ដោយផ្អែកលើការបំពេញតាមលក្ខខណ្ឌតម្រូវដូចមានកំណត់ក្នុងគោលការណ៍ណែនាំនេះ បទប្បញ្ញត្តិពាក់ព័ន្ធ និងការតម្រូវរបស់ **ន.ម.ភ.**។

**២-លក្ខខណ្ឌតម្រូវ**

ដើម្បីទទួលបានការអនុញ្ញាតប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបំពេញតាមលក្ខខណ្ឌតម្រូវដូចខាងក្រោម៖

ក- មានប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ដែលអភិវឌ្ឍដោយក្រុមហ៊ុនផ្ទាល់ ឬផ្គត់ផ្គង់ដោយក្រុមហ៊ុនផ្គត់ផ្គង់បច្ចេកវិទ្យាព័ត៌មានដែលទទួលបានការអនុញ្ញាតពី **ន.ម.ភ.**។

ខ- មានសៀវភៅណែនាំស្តីពីដំណើរការនៃការប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ។

គ- មាននីតិវិធី និងយន្តការតាមប្រព័ន្ធអនឡាញក្នុងការបំពេញកាតព្វកិច្ចតាមច្បាប់ក្នុងការសិក្សាឱ្យបានច្បាស់លាស់ពីព័ត៌មានទាក់ទងនឹងអតិថិជន អនុលោមតាមប្រការ៧ និងប្រការ៨ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មឧបករណ៍និស្សន្ទ និងគោលការណ៍ណែនាំស្តីពីទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ ទម្រង់កិច្ចព្រមព្រៀងអតិថិជន និងទម្រង់សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ សម្រាប់ការជួញដូរឧបករណ៍និស្សន្ទ។

ឃ- មាននីតិវិធី និងយន្តការតាមប្រព័ន្ធអនឡាញក្នុងការពន្យល់ខ្លឹមសារនិងបំពេញកិច្ចព្រមព្រៀងអតិថិជន ចុះកិច្ចព្រមព្រៀងជាមួយអតិថិជន និងទទួលសេចក្តីប្រកាសទទួលស្គាល់ហានិភ័យពីអតិថិជនដោយអនុលោមតាមប្រការ៩ នៃប្រកាសស្តីពីក្រមសីលធម៌វិជ្ជាជីវៈសម្រាប់អាជីវកម្មឧបករណ៍និស្សន្ទ និងគោលការណ៍ណែនាំស្តីពីទម្រង់ពាក្យស្នើសុំបើកគណនីជួញដូរ ទម្រង់កិច្ចព្រមព្រៀងអតិថិជន និងទម្រង់សេចក្តីប្រកាសទទួលស្គាល់ហានិភ័យ សម្រាប់ការជួញដូរឧបករណ៍និស្សន្ទ។

ង- មាននីតិវិធី និងយន្តការតាមប្រព័ន្ធអនឡាញក្នុងការពន្យល់លម្អិតដល់អតិថិជននូវនីតិវិធីនៃការដាក់ ដក ផ្ទេរ និងទូទាត់សាច់ប្រាក់ អនុលោមតាមបទប្បញ្ញត្តិ គោលការណ៍ណែនាំ ឬការតម្រូវរបស់ **ន.ម.ភ.**។

ច- មាននីតិវិធី និងយន្តការតាមប្រព័ន្ធអនឡាញក្នុងការពិនិត្យ ផ្ទៀងផ្ទាត់ និងអនុម័តលើការស្នើសុំបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញរបស់អតិថិជន។

ឆ- មានយន្តការក្នុងការតភ្ជាប់ ឬបង្កើតគណនីជួញដូររបស់អតិថិជននៅក្នុងវេទិកាជួញដូរឧបករណ៍និស្សន្ទ។

ជ- មានយន្តការគ្រប់គ្រង និងថែរក្សាសន្តិសុខសាយប័រដែលអាចទប់ស្កាត់ ឆ្លើយតប និងការការពារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន រួមទាំងហេដ្ឋារចនាសម្ព័ន្ធបណ្តាញ ប្រតិបត្តិការ និងកម្មវិធី ពីការជ្រៀតចូល និងការវាយប្រហារគ្រប់រូបភាព ជាពិសេសតាមប្រព័ន្ធអ៊ីនធឺណិត។

ឈ- មានយន្តការគ្រប់គ្រងនិងថែរក្សាសុវត្ថិភាព និងឯកជនភាពនៃទិន្នន័យរបស់អតិថិជន ដោយមិនត្រូវបានចែករំលែក លួចយក ឬយកទៅប្រើប្រាស់ដោយគ្មានការអនុញ្ញាតពីម្ចាស់ទិន្នន័យ។

ញ- សាកល្បងប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ដោយមានលទ្ធផលអាចទទួលយកបាន។

## ៣-ភារកិច្ចរបស់ឈ្មួញជើងសាឧបករណ៍និស្សន្ទ

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវ៖

ក- ស្នើសុំការអនុញ្ញាតជាមុនពី **ន.ម.ក.** មុននឹងផ្លាស់ប្តូរ ឬកែប្រែផ្នែកឬមុខងារណាមួយនៃប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ដែលទទួលបានការអនុញ្ញាត។

ខ- ជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ក.** ក្នុងករណីបន្ទាប់ពីកើតមានឧបទ្ទវហេតុប្រតិបត្តិការពាក់ព័ន្ធនឹងប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ឬមានការវាយប្រហារសាយប័រ និងវិធានការក្រុមហ៊ុនបានចាត់ ដើម្បីដោះស្រាយឧបទ្ទវហេតុ និងការវាយ-ប្រហារទាំងនោះ។

គ- ជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **ន.ម.ក.** ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់ព័ន្ធនឹងពាក្យស្នើសុំការអនុញ្ញាតប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ។

ឃ- រក្សាឱ្យបានត្រឹមត្រូវនូវកំណត់ត្រាពាក់ព័ន្ធនឹងដំណើរការប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧប-ករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញរបស់អតិថិជននីមួយៗ សម្រាប់ការត្រួតពិនិត្យអនុលោមភាព និងការធ្វើសវនកម្ម។

ង- ប្រាកដថា បុគ្គលិកដែលទទួលខុសត្រូវពាក់ព័ន្ធនឹងការបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ បានទទួលការបណ្តុះបណ្តាល មានចំណេះដឹង និងជំនាញគ្រប់គ្រាន់ក្នុងការបំពេញការងារ និងអនុវត្តនីតិវិធីពាក់ព័ន្ធ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទមិនត្រូវធ្វើការផ្សព្វផ្សាយ ឬដាក់បង្ហាញព័ត៌មានពាក់ព័ន្ធនឹងប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញដែលមិនទាន់ទទួលបានការអនុញ្ញាតពី **ន.ម.ក.**។

## ៤-ការវាយតម្លៃ

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវធ្វើការវាយតម្លៃភាពសមស្របនិងប្រសិទ្ធភាពនៃដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយកមុននឹងដាក់ឱ្យអនុវត្ត និងត្រូវធ្វើការវាយតម្លៃឡើងវិញយ៉ាងតិចមួយដងក្នុងមួយឆ្នាំ បន្ទាប់ពីការដាក់ឱ្យអនុវត្ត។ រាល់ការវាយតម្លៃត្រូវធ្វើឡើងដោយអ្នកវាយតម្លៃដែលមានសមត្ថភាព ចំណេះដឹង បទពិសោធន៍ និងធនធានពាក់ព័ន្ធសម្រាប់ការវាយតម្លៃ។

វិសាលភាពនៃការវាយតម្លៃដូចមានចែងក្នុងកថាខណ្ឌទី១ នៃចំណុចទី៤ នេះ ត្រូវគ្របដណ្តប់យ៉ាងហោចណាស់នូវចំណុចដូចខាងក្រោម៖

ក- ដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយក មានភាពសមស្រប និងប្រសិទ្ធភាពក្នុងការកំណត់អត្តសញ្ញាណពិតប្រាកដរបស់អតិថិជន ដោយពិចារណាលើកត្តានៃការរីកចម្រើននៃបច្ចេកវិទ្យា និងកម្រិតស្មុគស្មាញនៃការលួចចូល (Hacking) និងការវាយប្រហារដែលមានលក្ខណៈក្លែងបន្លំ (Spoofing attacks)។

ខ- ដំណើរការត្រួតពិនិត្យតាមដានជាប្រចាំ និងការវាយតម្លៃឡើងវិញ ដោយរួមបញ្ចូលទាំងការវាយតម្លៃឡើងវិញនៃប្រព័ន្ធសម្រាប់បញ្ជាក់ពីភាពត្រឹមត្រូវនៃឯកសារអត្តសញ្ញាណ និងសម្រាប់ផ្ទៀងផ្ទាត់អត្តសញ្ញាណ ត្រូវបានអនុវត្តប្រកបដោយភាពសមស្រប និងប្រសិទ្ធភាព។

គ- ដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយក រួមទាំងការផ្លាស់ប្តូរ ឬកែប្រែផ្នែកឬមុខងារណាមួយនៃប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ត្រូវបានអនុវត្តដោយត្រឹមត្រូវ និងត្រូវបានធ្វើការសាកល្បងដោយមានលទ្ធផលអាចទទួលយកបាន។

ឃ- គ្រប់លក្ខខណ្ឌតម្រូវដូចមានចែងក្នុងចំណុចទី២ នៃគោលការណ៍ណែនាំនេះត្រូវបានបំពេញ។

សម្រាប់ការវាយតម្លៃនីមួយៗ ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវរៀបចំរបាយការណ៍វាយតម្លៃដែលត្រូវគ្របដណ្តប់យ៉ាងហោចណាស់នូវចំណុចដូចខាងក្រោម៖

ក- ការរៀបរាប់លម្អិតនៃដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយក។

ខ- ព័ត៌មានលម្អិតនៃការងារដែលបានធ្វើ ដោយរួមបញ្ចូលទាំងសេចក្តីពន្យល់នៃវិសាលភាព និងវិធីសាស្ត្រនៃការវាយតម្លៃ។

គ- សេចក្តីបញ្ជាក់ថា ដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយក គឺមានភាពសមស្រប និងប្រសិទ្ធភាពក្នុងការកំណត់អត្តសញ្ញាណពិតប្រាកដរបស់អតិថិជន និងបង្ហាញពីមូលដ្ឋាននិងមូលហេតុនៃការចេញសេចក្តីបញ្ជាក់នេះ។

ឃ- សេចក្តីពន្យល់ពីភាពចន្លោះខ្វះខាតសក្តានុពលនៃការវាយតម្លៃ ព្រមទាំងដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយក (ប្រសិនបើមាន)។

ង- អនុសាសន៍កែលម្អដំណើរការ និងបច្ចេកវិទ្យាដែលបានទទួលយក (ប្រសិនបើមាន)។

ច- ការឆ្លើយតបរបស់ថ្នាក់ដឹកនាំនៃឈ្មួញជើងសាឧបករណ៍និស្សន្ទចំពោះអនុសាសន៍កែលម្អរបស់អ្នកវាយតម្លៃ ស្ថានភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តជាដំណាក់កាលនៃអនុសាសន៍ (ប្រសិនបើមាន)។

**៥-កម្រៃ**

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតជូន **ន.ម.ក.** ក្នុងករណីដូចខាងក្រោម៖

ក- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិតចំនួន ៤០០.០០០ (បួនរយពាន់) រៀល ចំពោះការស្នើសុំការអនុញ្ញាតប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ។

ខ- ថ្លៃពាក្យស្នើសុំចំនួន ២០.០០០(ម្ភៃពាន់) រៀល ក្នុងមួយច្បាប់ និងសោហ៊ុយសិក្សាសំណុំលិខិត ចំនួន ២០០.០០០(ពីររយពាន់) រៀល ចំពោះការស្នើសុំផ្លាស់ប្តូរ ឬកែប្រែផ្នែកឬមុខងារណាមួយ នៃប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ។

ឈ្មួញជើងសាឧបករណ៍និស្សន្ទត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតចូលក្នុងគណនីរបស់ **ន.ម.ក.**។

ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមគោលការណ៍ណែនាំនេះ មិនត្រូវបានប្រគល់ជូនឈ្មួញជើងសាឧបករណ៍និស្សន្ទវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

**៦- ការដកហូតការអនុញ្ញាត**

**ន.ម.ក.** អាចដកហូតការអនុញ្ញាតប្រើប្រាស់ប្រព័ន្ធបើកគណនីជួញដូរឧបករណ៍និស្សន្ទតាមប្រព័ន្ធអនឡាញ ក្នុងករណីឈ្មួញជើងសាឧបករណ៍និស្សន្ទមិនអនុវត្តតាមគោលការណ៍ណែនាំនេះ បទប្បញ្ញត្តិពាក់ព័ន្ធ ឬការណែនាំរបស់ **ន.ម.ក.**។

ថ្ងៃ សុក្រ ៨ កើត ខែ បុស្ស ឆ្នាំខាល ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ២០២២

**និយ័តករមូលបត្រកម្ពុជា**